ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ដំណើរចូលរួមវេទិកាប៉េកាំងសៀងសាន លើកទី១២ របស់ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន

តបតាមការអញ្ជើញរបស់ **ឯកឧត្តម នាយឧត្តមនាវី តុង ជីន** (Dong Jun) រដ្ឋមន្ត្រីការពារជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់ ចូលរួមវេទិកាប៉េកាំងសៀងសាន លើកទី១២ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៧-១៩ ខែកញ្ញា ឆ្នាំ២០២៥ នៅទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។

ក្នុងឱកាស នៃការចូលរួមវេទិកា **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នឹងអញ្ជើញឡើងថ្លែងសុន្ទរកថាក្នុងសម័យប្រជុំពេញអង្គទី៤ ស្តីពី "ការកសាងសន្តិភាពតំបន់តាមរយៈកិច្ចសន្ទនា និងការពិគ្រោះយោបល់" (Building Reginal Peace Through Dialogue and Consultation)។

នៅក្នុងឱកាសនោះដែរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** នឹងចូលជួបសម្តែងការគួរសម និងពិភាក្សាការងារទ្វេភាគីជាមួយ **ឯកឧត្តម នាយឧត្តមនាវី តុង ជីន** រដ្ឋមន្ត្រីការពារជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងគោលបំណងដើម្បីជំរុញចំណងទំនាក់ទំនង មិត្តភាពដែកថែប និងកិច្ចសហប្រតិបត្តិការការពារជាតិរវាងប្រទេសទាំងពីរឲ្យកាន់តែស៊ីជម្រៅថែមទៀត។ ទន្ទឹមនោះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** ក៏នឹងមានជំនួបទ្វេភាគីជាមួយរដ្ឋមន្ត្រីការពារជាតិ និងប្រធានប្រតិភូ នៃបណ្តាប្រទេសជាមិត្ត ដូចជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋសង្គមនិយមវៀតណាម ម៉ាឡេស៊ី និងសិង្ហបុរី ក៏ដូចជាជំនួប ជាមួយដៃគូសន្ទនាមួយចំនួនទៀត ដើម្បីពង្រឹងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការការពារជាតិ និងសន្តិសុខជាមួយគ្នា។

ថ្ងៃអង្គារ ៩ រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៥

វិថីហ្សកឌឺមីគ្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ generalsec@mod.gov.kh

Unofficial Translation

# Press Release

# On

# His Excellency General Tea Seiha, Deputy Prime Minister and Minister of National Defence, Attending the 12th Beijing Xiangshan Forum in Beijing, People's Republic of China

At the invitation of **His Excellency Admiral Dong Jun**, Minister of National Defence of the People's Republic of China, **His Excellency General Tea Seiha**, Deputy Prime Minister, Minister of National Defence, will lead a high-level military delegation to attend the 12th Beijing Xiangshan Forum, to be held from September 17 to 19, 2025, in Beijing, People's Republic of China.

On the occasion of attending the Forum, **His Excellency Deputy Prime Minister, Minister of National Defence**, will deliver a speech at the fourth plenary session on "**Building Regional Peace Through Dialogue and Consultation.**"

On this occasion, **His Excellency Deputy Prime Minister** will pay a courtesy call on and hold bilateral discussions with **His Excellency Admiral Dong Jun**, Minister of National Defence of the People's Republic of China, with the aim of further strengthening the **ironclad friendship** and defence cooperation between the two countries. In addition, **His Excellency Deputy Prime Minister, Minister of National Defence** will also hold bilateral meetings with the Ministers of National Defence and heads of delegations from friendly nations including the Lao People's Democratic Republic, the Socialist Republic of Vietnam, Malaysia, and Singapore as well as engage in discussions with other dialogue partners to broaden and deepen defence and security cooperation.

Phnom Penh, 16 September 2025